UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

OHCHR

## សេចក្តីថ្លែងការណ៍របស់ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

**ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩**

## ការបណ្តេញចេញអ្នកភូមិដីក្រហម : ការដើរថយក្រោយ សម្រាប់នីតិរដ្ឋ

យើងបានឃ្លាំមើលដោយរន្ធត់នូវព្រឹត្តិការណ៍បណ្តេញចេញភ្លាមៗ និងប្រកបដោយអំពើហិង្សា ក្នុងអំឡុងពេលបុណ្យចូលឆ្នាំតាមប្រពៃណីជនជាតិចិននាចុងសប្តាហ៍ ដល់សហគមន៍ដីក្រហមដែលនៅសេសសល់ ។ បន្ទាប់ពីរយៈពេលជិតមួយខែនៃការចរចារដែលពន្យារពេលដ៏យូរ រវាងអ្នកភូមិដីក្រហម ក្រុមហ៊ុនសំណង់7NG និងសាលាក្រុង ដោយមានបំណងស្វែងរកការដោះស្រាយ ដែលអាចព្រមព្រៀងគ្នាទៅវិញទៅមកនៃការទាមទារសំណងនោះមក ក្រុមហ៊ុនបានដកខ្លួនជាឯកតោភាគីពីការពិភាក្សា ហើយអនុវត្តបទបញ្ជានៃការបណ្តេញចេញដែលបាន ពន្យារកន្លងមក ដោយភ្នាក់ងារអនុវត្តច្បាប់ ។ ការបណ្តេញចេញនេះត្រូវបានធ្វើឡើងនាពេលពាក់កណ្តាលយប់ ដោយការប្រើគ្រឿងចក្រឈូសឆាយ ឧស្ម័នបង្ហូរទឹកភ្នែក កាំភ្លើងគ្រាប់ជ័រ ដំបងឆក់ និងកម្មករប្រដាប់ដោយដំបង និងពូថៅធ្វើការវាយកំទេចលំនៅដ្ឋាន ។ គ្រួសារទាំងអស់ត្រូវបានគេបណ្តេញចេញពីផ្ទះដោយឃោរឃៅ ហើយអ្នកទាំងឡាយណាដែលតស៊ូប្រឆាំងនិងប៉ុនប៉ងការពារទ្រព្យសម្បត្តិរបស់គេ ត្រូវបានគេវាយតប់ និងទាញចេញពីផ្ទះដោយប្រើកំលាំង ។ អ្នកភូមិទាំងនោះត្រូវបានដេញចេញអោយឈរតាមថ្នល់មើលសកម្មភាពបំផ្លិចបំផ្លាញផ្ទះរបស់គេ ។ នាពេលព្រលឹមស្រាងៗ អ្វីដែលនៅសេសសល់គឺគំនរកំទេចកំទី និងផេះផង់ ។

នេះគឺជាព្រឹត្តិការណ៍ចុងក្រោយថ្មីមួយ ចំពោះករណីនៃការបណ្តេញចេញប្រកបដោយហិង្សា ក្នុងចំណោមករណីជាច្រើនដែលកើតមានជាបន្តបន្ទាប់អស់រយៈពេលជាយូរមកហើយនៅទីក្រុង ។

ភាគច្រើននៃអ្នកភូមិដីក្រហម ក៏ដូចគ្នានឹងអ្នកទាំងឡាយ ដែលរស់នៅតំបន់បាសាក់ដែរត្រូវបានគេបង្ខំអោយចេញពីដី និងផ្ទះកាលពីមុន ហើយអ្នកទាំងឡាយដែលរស់នៅតំបន់ជិតខាង គឺ "ក្រុម៧៨ និង"ប៊ូឌីង" ក៏នឹងអាចត្រូវគេបណ្តេញចេញនាពេលអនាគតនោះ បានរស់នៅក្នុងសង្កាត់នេះចាប់តាំងពីដើមទស្សវត្ស៨0មកម្ល៉េះ នៅពេល

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

ដែលប្រជាពលរដ្ឋត្រូវបានគេអនុញ្ញាតអោយត្រឡប់ចូលទីក្រុង ដែលគ្មានមនុស្សរស់នៅ បន្ទាប់ពីរបបខ្មែរក្រហម ។ ចាប់ពីពេលនោះមក ពួកគេរស់នៅដោយក្សេមក្សាន្តក្នុងតំបន់នេះ ។ ការរស់នៅក្នុងស្ថានភាពបែបនេះ ភាគច្រើនបំផុត នៃអ្នកភូមិទាំងនេះ បំពេញបាននូវលក្ខ័ណ្ឌ សម្រាប់ទទួលសិទ្ធិភោគៈ ក្រោមច្បាប់ភូមិបាលឆ្នាំ ២០០១ ។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានការសម្រេចចិត្តណាមួយត្រូវបានធ្វើឡើងដោយអាជ្ញាធរទេ អំពីសិទ្ធិកម្មសិទ្ធិនេះ ដោយទុកចោលមិនអើពើចំពោះសិទ្ធិកម្មសិទ្ធិនេះ និងបង្ហាញអោយឃើញនូវការសម្រេចចិត្ត និង ការរំលោភបំពានដោយទំនើងចិត្ត ។ អាជ្ញាធរក្រុងបានទទួលបរាជ័យដើម្បីលើកកំពស់ច្បាប់ និងការពារសិទ្ធិអ្នកភូមិដីក្រហមរបស់ខ្លួន ។

នៅឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អោយសហគមន៏នេះនូវដីសម្បទានសង្គមកិច្ចនៅនឹងកន្លែង គឺជាការរៀបចំមួយ ដែលនៅក្រោមច្បាប់ភូមិបាលត្រូវគេសន្មត់ថា ត្រូវការពារសិទ្ធិរបស់សហគមន៏ក្រីក្រចំពោះដីធ្លីរបស់គេ ។ តាមកិច្ចព្រមព្រៀងនេះ ការបណ្តេញចេញនេះ គឺជាការរំលោភសិទ្ធិដីធ្លីរបស់ពួកគេ និងរំលោភច្បាប់ភូមិបាល ដែលការពារទ្រព្យសម្បត្តិឯកជនរបស់ប្រជាពលរដ្ឋកម្ពុជា ។ ទាំងរដ្ឋធម្មនុញ្ញនិងច្បាប់ភូមិបាលបានចែងថាគ្មាន នរណាម្នាក់អាចដកហូតដីធ្លីរបស់ពួកគេដោយទំនើងចិត្ត ដោយគ្មានការផ្តល់នូវសំណងត្រឹមត្រូវឡើយ ។ គារមិនយកចិត្តទុកដាក់ដោយឥតលាក់លាម ចំពោះគោលការណ៏ជាមូលដ្ឋានទាំងនេះ បង្ហាញអោយឃើញគ្រឹះនៃភាពទន់ខ្សោយនៃនីតិរដ្ឋ នៅពេលដែលប្រជាពលរដ្ឋសាមញ្ញប្រឈមមុខនឹងប្រយោជន៏ដ៏ធំរបស់ក្រុមហ៊ុន ដែលគាំទ្រដោយអាជ្ញាធរសាធារណៈ ។ ការដកហូតទ្រព្យសម្បត្តិឯកជន ដែលកាន់កាប់ដោយស្របច្បាប់ ឬមានសិទ្ធិកាន់កាប់តាមផ្លូវច្បាប់ចាត់ទុកថាជា  បទឧក្រិដ្ឋមួយក្រោមច្បាប់កម្ពុជា ។

ការបណ្តេញចេញនេះគេអាចបញ្ជៀសបាន ។ កាលពីជាង៣ឆ្នាំមុន ការចរចារត្រូវបានផ្តួចផ្តើមគំនិតរវាងក្រុមហ៊ុន7NG និងអ្នកភូមិ ។ ក្រុមហ៊ុនបានស្នើជម្រើសសាងសង់ផ្ទះ នៅតំបន់លំនៅដ្ឋានបង្កើតថ្មី គឺភូមិដំណាក់ត្រយឹង ខ័ណ្ឌដង្កោ ។ ក្រុមហ៊ុនបានរៀបចំប្រព័ន្ធទឹក និងភ្លើងអគ្គិសនីនៅតំបន់នោះ សាងសង់ផ្ទះល្វែង និងផ្សារស្ថិតនៅក្បែររោងចក្រកាត់ដេរ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុននេះ មានកម្មករចំនួន ២000នាក់កំពុងបំរើការងារ ។ ក្នុងការប្រៀបធៀបនឹងការអនុវត្តន៏កាលពីមុន ដំណើរការនេះជាដំណើរការគួរអោយស្វាគមន៏ ដោយមានសំណងសមរម្យជាងមុន ។

ចាប់តាំងពីពេលនោះមកតម្លៃដីចេះតែកើនឡើងយ៉ាងសន្ធឹកសន្ធាប់ ហើយដោយសារតែបញ្ហាការកើនឡើងតម្លៃដីនេះហើយ ការទាមទាររបស់អ្នកភូមិ ដែលនៅសេសសល់សម្រាប់ធ្វើការពិចារណាសំណងសមល្មមនឹងតម្លៃទីផ្សារ ។ នេះគឺជាការទាមទារស្របច្បាប់ ។ នៅខណៈដែលអ្នកភូមិចំនួន១៣00គ្រួសារបានព្រមព្រៀងផ្លាស់ប្តូរទីកន្លែងទៅកាន់តំបន់ដំណាក់ត្រយឹង ហើយក្រុមដែលនៅសេសសល់ចំនួន១៥0គ្រួសារ ដោយរួមទាំងយ៉ាងហោចណាស់៩0គ្រួសារ ទាមទារសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ ហើយមិនព្រមទទួលយកសំណើរបស់ក្រុមហ៊ុន ដែលគេគិតថា ទាបជាងតម្លៃទីផ្សារឆ្ងាយ ។ ពួកគេបានប្រឆាំងនឹងសម្ពាធ ការគំរាមគំហែង ការបំភិតបំភ័យ និងចំណាត់ការផ្លូវច្បាប់របស់ក្រុមហ៊ុន ប្រឆាំងនឹងសមាជិក៩នាក់របស់ខ្លួន ដោយមានគោលបំណងដាក់ការបង្ខិតបង្ខំលើការទាមទាររបស់ប្រជា

ពលរដ្ឋ ។ ក្នុងដំណើរការនេះ អ្នកភូមិក្នុងសហគមន៍ត្រូវបានគេលាបពណ៌យ៉ាងអយុត្តិធម៌ថាជា "ក្រុមអនាធិបតេយ្យ និងឱកាស និយម" ហើយថាតំបន់នេះជា កន្លែងហិង្សា លួច ប្លន់ គ្រឿងញៀន និងពេស្យាចារ្យ ។

អង្គការសង្គមស៊ីវិលបានធ្វើការងារនេះអស់រយៈពេលជាច្រើនឆ្នាំ ជាមួយសហគមន៍បានេះ ដោយធ្វើការអំពាវ-នាវអោយអនុវត្តច្បាប់ភូមិបាល និងផ្តល់សំណងសមរម្យ ។ ការិយាល័យរបស់យើងបានគាំទ្រអនុសាសន៍ទាំងនេះ ហើយបានធ្វើការយ៉ាងសកម្មដើម្បីទទួលបានការពន្យារពេលច្រើនថែមទៀត និងបានលើកទឹកចិត្តសាលាក្រុង និងក្រុមហ៊ុនដើម្បីបន្តការចរចារជាមួយអ្នកភូមិ ក្នុងគោលបំណងដើម្បីសម្រេចអោយបាននូវដំណោះស្រាយដែលអាចព្រមព្រៀងគ្នាទៅវិញទៅមកដោយសន្តិវិធី និងយុត្តិធម៌ ។ សាលាក្រុងទទួលយកអនុសាសន៍របស់សង្គមស៊ីវិលនៅចុងខែធ្នូឆ្នាំ២០០៨ ហើយការចរចារធ្វើបន្ត ។ ក្រុមចរចារត្រូវបានរំលាយចោល នៅថ្ងៃទី១៦ ខែមករា តែការចរចារជាបុគ្គលបានបន្តរហូតដល់ថ្ងៃទី២៤ ខែមករា ។ ការបណ្តេញចេញនេះត្រូវបានគេបញ្ជាធ្វើភ្លាមៗនៅថ្ងៃបន្តបន្ទាប់ និងអនុវត្តភ្លាមៗដូច្នេះធ្វើអោយឱកាសស្វែងរកដំណោះស្រាយដោយយុត្តិធម៌ និងសន្តិវិធីទទួលបរាជ័យ ។ នៅពេលដែលអ្នកភូមិបានបាត់បង់ដីផ្ទះ និងទ្រព្យសម្បត្តិរបស់ពួកគេ ពួកគេនៅតែមានសិទ្ធិទទួលតាមផ្លូវច្បាប់នូវ សំណងដោយសមរម្យ ។ នេះគឺជាការទទួលខុសត្រូវរបស់សាលាក្រុង និងក្រុមហ៊ុនក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ការិយាល័យយើងសូមផ្តល់អនុសាសន៍ថា សំណើចុងក្រោយដែលផ្តល់ដោយក្រុមហ៊ុន7NG នូវសំណងជាមធ្យមចំនួន២០០០០ ដុល្លារអាមេរិកដល់អ្នកភូមិត្រូវតែគិតគូ ។ ការផ្តល់ផ្ទះណាមួយស្មើឡើងជាផ្នែកនៃសំណងនេះត្រូវបំពេញអោយបាននូវបទដ្ឋានជាមូលដ្ឋាន ក្នុងក្របខ័ណ្ឌទទួលបានសេវាប្រើប្រាស់ទឹក អនាម័យ ភ្លើងអគ្គិសនី ការថែរក្សាសុខភាពនិងការអប់រំ ។

នេះគឺជាព្រឹត្តិការណ៍ថ្មីបំផុតនៃការបណ្តេញចេញប្រកបដោយអំពើហិង្សា ក្នុងរូបភាពនៃការអភិវឌ្ឍន៍ទីក្រុង និង "ការកែលំអសោភ័ណភាពទីក្រុង" ដែលដើរផ្ទុយនឹងគោលនយោបាយរបស់រដ្ឋាភិបាលនៃអភិបាលកិច្ចល្អ នីតិរដ្ឋ ការអភិ-វឌ្ឍន៍ធនធានមនុស្ស និងការកាត់បន្ថយភាពក្រីក្រ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍នានា ។ បើច្បាប់ត្រូវបានគេអនុវត្តតាំងពីដំណាក់កាលដំបូងបំផុតនៃដំណើរការនេះ នោះដំណោះស្រាយតាមផ្លូវច្បាប់ និងសន្តិវិធីត្រូវសម្រេចបាន ។ វាមិនទាន់ហួសពេលទេសម្រាប់សាលាក្រុង រដ្ឋាភិបាល និងក្រុមហ៊ុនដែលត្រូវបង្ហាញថា ច្បាប់ភូមិបាលអាចលើកកំពស់ និងអនុវត្តដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់ ដោយមិនគិតពីអ្នកមាន អ្នកក្រ ឬឋានៈសង្គមរបស់ពួកគេឡើយ ។

oO0Oo